**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋានពន្ធដារ**

លេខ ២៣៩១៣.....អពដ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

L20200922002 | TD3461

ថ្ងៃអង្គារ ៤កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក-លោកស្រីនាយក**

| | |
|---|---|
| ឈ្មោះអង្គការ | ÷ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| ជាអក្សរឡាតាំង | ÷ COOPERATION COMMITTEE FOR CAMBODIA |
| លេខអត្តសញ្ញាណកម្ម | ÷ K002-100054242 ចុះបញ្ជីនៅ÷ សាខាពន្ធដារខណ្ឌចំការមន |
| សកម្មភាពអាជីវកម្ម | ÷ អភិបាលកិច្ចល្អ ការសិក្សានិងស្រាវជ្រាវ និងការកសាងបណ្តាញ |
| អាសយដ្ឋាន | ÷ #៩-១១ ផ្លូវ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ |

**កម្មវត្ថុ÷** ករណីស្នើសុំអគ្គនាយកដ្ឋានពន្ធដារជួយសម្របសម្រួលដោះស្រាយការលើកលែងការបង់ប្រាក់ពន្ធ និងការប្រាក់ដែលអង្គការក្រុមកុមារកម្ពុជាដើម្បីការអប់រំ ជំពាក់នៅមុនការចុះបញ្ជីពន្ធដារ របស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។

**យោង ÷**
- ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងធ្វើវិសោធនកម្មបន្តបន្ទាប់
- ប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- សេចក្តីណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីពន្ធដារ
- សេចក្តីណែនាំលេខ ០១៦ សហវ.អពដ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីការពន្យារពេលអនុវត្តសេចក្តីណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីពន្ធដារ
- លិខិតលេខ ២៨៩៦ អពដ.សខ.សរ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សាខាពន្ធដារខេត្តសៀមរាប
- លិខិតលេខ ០១៣៧ អពដ.ន.ពតម ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- លិខិតលេខ ០៣០៨ អពដ.ន.ពតម ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- លិខិតលេខ ១២១៥ អពដ.សខ.សរ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់សាខាពន្ធដារខេត្តសៀមរាប
- លិខិតចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប លោក-លោកស្រីនាយកអង្គការ ជ្រាបថា អគ្គនាយកដ្ឋានពន្ធដារ បានពិនិត្យសំណើសុំអគ្គនាយកដ្ឋានពន្ធដារជួយសម្របសម្រួលដោះស្រាយការលើកលែងការបង់ប្រាក់ពន្ធ និងការប្រាក់ដែលអង្គការក្រុមកុមារកម្ពុជាដើម្បីការអប់រំ ជំពាក់នៅមុនការចុះបញ្ជីពន្ធដារ របស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជារួចរាល់។ ផ្អែកតាមការពិនិត្យលើរបាយការណ៍របស់សាខាពន្ធដារខេត្តសៀមរាប និងវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អង្គការក្រៅរដ្ឋាភិបាល) ការចុះបញ្ជីរបស់អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ មានប្រសិទ្ធភាពចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ តទៅ។

អនុលោមតាមកថាខណ្ឌ៣ នៃសេចក្តីណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីពន្ធដារ ចែងថា÷ "៣-ក្រោយពេលចុះបញ្ជីពន្ធដារដូចមានចែងក្នុងចំណុច១ និងចំណុច២ ខាងលើ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវអនុវត្តកាតព្វកិច្ចសារពើពន្ធជាអាទិ៍មាន ការដាក់លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក និងពន្ធនានាទាក់ទិននឹងសកម្មភាពជាគោលដៅសុទ្ធសាធ និងមិនស្ថិតក្នុងគោលដៅសុទ្ធសាធ ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដោយពុំមានលក្ខណៈប្រតិសកម្មឡើយ។"



អគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

អនុលោមតាមសេចក្តីជូនដំណឹងលេខ ០១៦ សហវ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីការពន្យារពេលអនុវត្តសេចក្តីណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីពន្ធដារ ចែងថា÷ *"...ដើម្បីផ្តល់លទ្ធភាពដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលមិនទាន់បានចុះបញ្ជីពន្ធដារឱ្យមានពេលវេលាគ្រប់គ្រាន់ក្នុងការចុះបញ្ជីពន្ធដារ ក៏ដូចជាការបំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចពន្យារពេលអនុវត្តសេចក្តីណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។"*

ផ្អែកតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងតាមការពិនិត្យខាងលើ អគ្គនាយកដ្ឋានពន្ធដារ សម្រេចអនុញ្ញាតលើកលែងពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធអាករនានា និងប្រាក់ទោសទណ្ឌ ដែលកើតមានឡើងមុនថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ដែលជាកាលបរិច្ឆេទមានប្រសិទ្ធភាពចុះបញ្ជីពន្ធដាររបស់អង្គការក្រុមការងារកម្ពុជាដើម្បីអប់រំ ដោយហេតុថា កាលបរិច្ឆេទនេះកើតឡើងមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្របតាមសេចក្តីណែនាំលេខ ០១៦ សហវ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីនាយកអង្គការ ជ្រាបនិងបន្តចូលរួមសហការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក-លោកស្រីនាយកអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ទទួលនូវការរាប់អាន ពីខ្ញុំ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ចម្លងជូន÷
- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- សាខាពន្ធដារខណ្ឌចំការមន
- សាខាពន្ធដារខេត្តសៀមរាប
- អង្គការក្រុមការងារកម្ពុជាដើម្បីអប់រំ
- ឯកសារ-កាលប្បវត្តិ